សម្លេងទុគ៌្គតជន-Voice of the Poor

ព្រឹត្តិប័ត្រពត៌មាន ABiC–ABiC Newsletter

លេខ ០០៦ មិនា ២០០៥ — ឆ្នាំទី២ / No. 006 March 2005 – Year 2

ឧបត្ថម្ភដោយ/supported by USAID តាមរយៈ/through ARD Inc.

| បញ្ជីអត្ថបទ | ទំព័រ |
|---|---|
| ១. ជ្រុលហួសទៅហើយ (Too Late, p. 1) | ... ១ |
| ២. ដីសម្បទានសេដ្ឋកិច្ច និង ការអភិវឌ្ឍន៍ (Economic Land Concession and Development, p. 3) | ... ៣ |

## ជ្រុលហួសទៅហើយ

កាលពីដើមខែមិនាកន្លងទៅនេះ ក្រុមហ៊ុនដាំដើមស្រល់ នៅខេត្តមណ្ឌលគីរី បានធ្វើប្រតិបត្តិការកាប់ឈើលើដី ដែលខ្លួនបានទទួលជាសម្បទានសេដ្ឋកិច្ចពីរាជរដ្ឋាភិបាលកម្ពុជា ។ ការកាប់ឈើនោះ បានចំពារចំពានទៅលើព្រៃកប់ខ្មោចដូនតារបស់ប្រជាជនជនជាតិភាគតិចព្នង នៅក្នុងឃុំដាក់ដាំ ស្រុកអូរាំង ខេត្តមណ្ឌលគីរី ។ ដោយអំពើនេះ ធ្វើឱ្យប៉ះពាល់ដល់ប្រពៃណី វប្បធម៌ ជំនឿ និង ព្រលឹងបុព្វបុរសរបស់ពួកគេ និង ដោយចង់ការពារព្រៃឈើ ប្រជាជនឃុំដាក់ដាំ ដែលបច្ចុប្បន្នកំពង់តែរៀបចំចងក្រងសហគមន៍ព្រៃឈើឱ្យស្របតាមច្បាប់ស្ដីពីព្រៃឈើ និង អនុក្រឹត្យស្ដីពីសហគមន៍ព្រៃឈើ បានធ្វើការស្នើសុំឱ្យមានអន្តរាគមន៍ពីរដ្ឋបាលព្រៃឈើនៅខេត្តមណ្ឌលគីរីដើម្បីបញ្ឈប់ប្រតិបត្តិការកាប់ឈើនៅព្រៃកប់ខ្មោចនោះ ។

ឆ្លើយតបទៅតាមសំណូមពររបស់ប្រជាជននៅក្នុងសហគមន៍ដាក់ដាំ រដ្ឋបាលព្រៃឈើនៅខេត្តមណ្ឌលគីរី បានធ្វើការកោះអញ្ជើញភាគីដែលពាក់ព័ន្ធទាំងអស់ដើម្បីប្រជុំពិភាក្សារកដំណោះស្រាយ ។ នៅក្នុងអង្គប្រជុំពិភាក្សា ភាគីដែលពាក់ព័ន្ធទាំងអស់ ជាពិសេសគឺតំណាងសហគមន៍ និង តំណាងក្រុមហ៊ុន បានពន្យល់អំពីទង្វើ និង ហេតុផលរបស់ពួកគេរៀងៗខ្លួន ។

តំណាងក្រុមហ៊ុនបានអះអាងថាពួកគេបានធ្វើការកាប់ឆ្ការតែតំបន់របស់គេតែប៉ុណ្ណោះ ។ ពួកគេមិនបានចំពារចំពានទៅលើដីដែលប្រជាជនកំពង់តែប្រើប្រាស់នោះឡើយ ។ ម្យ៉ាងវិញទៀត ក្រុមហ៊ុនក៏ពុំបានដឹងថាព្រៃនោះជាព្រៃកប់ខ្មោចរបស់ប្រជាជនមូលដ្ឋានដែរ ។

តំណាងសហគមន៍បានតបថា ដីព្រៃនោះមិនអាចអនុញ្ញាតឱ្យធ្វើអ្វីឡើយ ព្រោះវាជាតំបន់

សម្រាប់តែកប់សព្វរបស់ដូនតា និង កូនចៅរបស់ពួកគេតែប៉ុណ្ណោះ ។ ការកាប់ឆ្ការព្រៃ និង ទន្ទ្រានដីនៅតំបន់នោះ ពិតជាធ្វើឱ្យមានការប៉ះពាល់ដល់ប្រពៃណី ជំនឿ វប្បធម៌ និង ព្រលឹងដូនតារបស់ពួកគេ ។ មិនតែប៉ុណ្ណោះ ការធ្វើបែបនេះនឹងធ្វើឱ្យព្រលឹងបុព្វបុរសរបស់ពួកគេខឹងសម្បារ ហើយអាចបង្កឱ្យមានកលយុគ និង ជំងឺដំកាត់ដល់អ្នកភូមិទៀតផង ។ អាស្រ័យហេតុដូច្នេះ ក្រុមហ៊ុនត្រូវតែបញ្ឈប់ជាបន្ទាន់ ។

មន្ត្រីរដ្ឋបាលព្រៃឈើខេត្តមណ្ឌលគីរី បានពន្យល់ និង លើកយកមាត្រានានានៃច្បាប់ព្រៃឈើ និង អនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើ មកបញ្ជាក់ឱ្យតំណាងក្រុមហ៊ុនបានស្វែងយល់ ។ មន្ត្រីរដ្ឋបាលព្រៃឈើខេត្តបានបញ្ជាក់ថាព្រៃអារក្ស-ព្រៃកប់ខ្មោចរបស់ប្រជាជនត្រូវបានច្បាប់ការពារទាំងស្រុង ។ ដូច្នេះក្រុមហ៊ុនត្រូវតែបញ្ឈប់សកម្មភាពនោះភ្លាម ។

យោងតាមប្រតិកម្ម និង ការបំភ្លឺទាំងអស់ខាងលើនេះ តំណាងក្រុមហ៊ុន ក៏បានទទួលយកសំណើរបស់ប្រជាជន និង បានសន្យាថានឹងបញ្ជាឱ្យកម្មកររបស់ក្រុមហ៊ុនបញ្ឈប់សកម្មភាពជាបន្ទាន់ ។ ប៉ុន្តែជាអកុសល ការបញ្ជាឱ្យបញ្ឈប់សកម្មភាពនោះ ត្រូវបានធ្វើឡើងមួយថ្ងៃក្រោយពីកិច្ចប្រជុំ ដែលនៅពេលនោះ កម្មកររបស់ក្រុមហ៊ុនបានកាប់ព្រៃ ឈើនោះអស់រលីងទៅហើយ ។

ការយោគយល់គ្នា កិច្ចព្រមព្រៀង និង ការសន្យា ពុំអាចបានជាផ្លែផ្កាអ្វីឡើយ ប្រសិនបើពុំមានវិធានការ និង ការជម្រុញឱ្យអនុវត្តកិច្ចព្រមព្រៀង និង កិច្ចសន្យាឱ្យបានទាន់ពេលវេលា ។ ភាពយឺតយ៉ាវតែងតែធ្វើឱ្យឱកាសល្អកន្លងផុត និង ធ្វើឱ្យអ្វីៗក្លាយជាអសារបង់ ដូចជាក្នុងករណីនេះជាដើម ។ ពាក្យស្លោកខ្មែរមួយឃ្លាបានពោលថា:

**Too Late**

In early March Pine Plantation Concession was clearing cemetery forest of Dak Dam commune. Local communities were unhappy with that and requested for intervention of local Forest Administration (FA) of Mondulkiri province.

Officials of FA in Mondulkiri convened a meeting of stakeholders concerned, especially community and company representatives. At the meeting representatives of the company and communities deliberated on the issue.

The company representatives said that they were clearing only land granted to them. The community representatives replied that that land was used as the burial site and could not be touched and thus the company's operation had to be halted right away. The FA officials presented certain articles of the Forest Law and Community Forest Sub-decree that provide for the protection of sacred forests and/or burial sites of local communities. The officials also stressed that the company act was legally unacceptable and should be backed off immediately before facing consequences.

The company representatives admitted that they were not aware that it was the burial site and that it was protected by the law. They then promised to call off the operation immediately as requested. However, the call-off order reached their field workers only a day later when all the trees disappeared. Just too late!

"បើធ្វើអ្វីត្រូវធ្វើឱ្យហើយ កុំទុកឡើយបង្កើតកេរ្តិ៍" បើពុំនោះសោតទេ យើងពិតជាអាចត្រឹមតែនិយាយថា ស្តាយណាស់ជ្រុលហួសទៅហើយ (!) ។

## ដីសម្បទានសេដ្ឋកិច្ច និង ការអភិវឌ្ឍន៍

ការសម្រេចចិត្តថ្មីៗចុងក្រោយរបស់រាជរដ្ឋាភិបាលក្នុងការបន្តផ្តល់ដីសម្បទានសេដ្ឋកិច្ច ដើម្បីជាការទាក់ទាញការវិនិយោគ និង ការអភិវឌ្ឍន៍សេដ្ឋកិច្ច គឺជាយុទ្ធសាស្ត្រមួយ ដែលគួរទទួលបានការពិចារណា និង ការគាំទ្រ ។ ប៉ុន្តែការសម្រេចចិត្តនេះ ហាក់បីដូចជាបានធ្វើឱ្យមានការព្រួយបារម្ភសម្រាប់សហគមន៍ផ្តល់ជំនួយ ពិសេសគឺធនាគារពិភពលោក អង្គការសង្គមស៊ីវិល និង ប្រជាកសិករកម្ពុជា ។ រាជរដ្ឋាភិបាលមានជំនឿថា យុទ្ធសាស្ត្រនេះនឹងអាចទាក់ទាញបាន នូវមូលធនសម្រាប់ការវិនិយោគ ដែលប្រទេសជាតិកំពុងតែត្រូវការជាចាំបាច់ ដើម្បីរួមចំណែកដល់ការបង្កើតការងារ នៅជនបទ ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និង ការកាត់បន្ថយភាពក្រីក្រ ។

ការព្រួយបារម្ភរបស់សហគមន៍ផ្តល់ជំនួយ អង្គការសង្គមស៊ីវិល និង ប្រជាកសិករកម្ពុជា ដែលធ្លាប់ទទួលបទពិសោធន៍ជូរចត់ជាមួយនឹងសម្បទានិកនៃដីសម្បទានសេដ្ឋកិច្ចកន្លងមក ក៏ជាប្រការគួរឱ្យពិចារណាដែរ ។ ការព្រួយបារម្ភទាំងនេះ ពិតជាមានហេតុផលដែលអាចយល់បាន ។

**Economic Land Concession and Development**

Latest decision of the Royal Government of Cambodia (RGC) on renewing economic land concession granting as a tool to attract investment needed to develop the nation's economy and poverty alleviation has caused a great concern for donor community, in particular the World Bank, civil society organizations (CSOs) and agrarian-based population. The RGC's decision should be supported, but the concern of donors, CSOs and Cambodian people should receive equal attention.

Poor economic concessions granting practice and performance were recognized by the Prime Minister himself at the last National Forum on Land held in October 2004. At the forum he expressed his resentment and concern about the way the economic concessions were granted and non-productiveness of the granted land, which had negative impacts on local communities, caused conflicts and in some instances the concessions included land where provincial government offices were standing, e.g. in Ratanakiri.

The process of granting economic concessions is not transparent, which never allowed for stakeholders' consultations. In addition many concessions are cleared only for logs and are not invested rendering land economically unproductive and degraded. A representative of a company raised similar concern at a recent Public-Private Sector Forum, and urged that the RGC reconsider carefully its policy on granting economic land concessions.

Economic land concessions will contribute to achieving the RGC's Rectangular Strategy for Growth, Employment, Equity and Efficency only if the process of granting and managing them provides for transparency and comprehensive stakeholders consultations that could ensure good and participatory governance principle.

កន្លងមកការផ្តល់ដីសម្បទានសេដ្ឋកិច្ច ត្រូវបានធ្វើឡើងដោយពុំមានតម្លាភាព ដែលជាទូទៅធ្វើនៅតែថ្នាក់ជាតិដោយពុំមានការពិនិត្យផ្ទៀងផ្ទាត់នៅមូលដ្ឋាន ជាពិសេសគឺគ្មានការផ្ទៀងផ្ទាត់ និង ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ ។ ក្នុងករណីខ្លះ ដីសម្បទានសេដ្ឋកិច្ចបានប៉ះពាល់ដល់ដីភូមិដ្ឋាន និង ដីកសិកម្មរបស់ប្រជាពលរដ្ឋមូលដ្ឋាន ដីស្ថាប័នរដ្ឋដែលកំពង់តែប្រើប្រាស់ និង ប៉ះពាល់ដល់ការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋជាដើម ។ល។ ឧទាហរណ៍: កាលពីខែតុលា ឆ្នាំ២០០៨កន្លងទៅនៅក្នុងវេទិការថ្នាក់ជាតិស្តីពីដីធ្លី លោកនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានថ្លែងដោយការខកចិត្តថា: វាគឺជាកំហុសរបស់មន្ត្រីរាជរដ្ឋាភិបាលដែលជាអ្នកផ្តល់ដីសម្បទានសេដ្ឋកិច្ចកន្លងមក ដែលបានធ្វើឱ្យប៉ះពាល់ទៅលើដីប្រើប្រាស់របស់ប្រជាពលរដ្ឋមូលដ្ឋាន និង មិនតែប៉ុណ្ណោះដីសម្បទានសេដ្ឋកិច្ចខ្លះថែមទាំងបានគ្របដណ្តប់ទៅដល់ទីស្នាក់ការស្ថាប័នរបស់ខេត្តទៀតផង ។ ឧទាហរណ៍ជាក់ស្តែងគឺនៅខេត្តរតនគីរី ។ លោកនាយករដ្ឋមន្ត្រីបានបន្តទៀតថា: ដូច្នេះត្រូវតែប្រុងប្រយ័ត្ន ហើយត្រូវតែមានយន្តការត្រឹមត្រូវមួយសម្រាប់ការផ្តល់ និង ការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច ។

ក្នុងករណីខ្លះទៀត សម្បទានិកមិនបានវិនិយោគលើដីដែលរដ្ឋាភិបាលបានផ្តល់ជូននោះឡើយ ។ ពួកគេខ្លះបានកាប់យកឈើធម្មជាតិដែលមាននៅលើដីសម្បទានធ្វើអាជីវកម្ម ហើយក៏ទុកដីឱ្យនៅចោលទំនេរដែលធ្វើឱ្យដីបាត់បង់គុណភាព និង រិចរិល ព្រមទាំងធ្វើឱ្យប៉ះពាល់ដល់ការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋមូលដ្ឋាន ដែលពឹងផ្អែកលើការរកអនុផលព្រៃ ឈើដូចជាវល្លិ៍ ផ្តៅ ជ័រ ថ្នាំ ទឹកឃ្មុំ ។ល។ នៅក្នុងវេទិការរវាងវិស័យសាធារណៈនិងឯកជនកន្លងទៅថ្មីៗនេះ តំណាងវិស័យឯកជនមួយរូបក៏បានលើកអំពីបញ្ហាដូចគ្នានេះ ហើយបានអំពាវនាវសុំឱ្យរាជរដ្ឋាភិបាលគិតគូរឱ្យបានហ្មត់ចត់អំពីគោលនយោបាយដីសម្បទានសេដ្ឋកិច្ច ។

សម្បទានិកខ្លះគ្រាន់តែយកដី ដែលខ្លួនទទួលបានជាសម្បទាននោះមកសម្រាប់តែរកអ្នកជួលបន្តតែប៉ុណ្ណោះ ។ នៅក្នុងវេទិការថ្នាក់ជាតិស្តីពីដីធ្លីដដែល លោកនាយករដ្ឋមន្ត្រីក៏បានថ្លែងថា: ដីសម្បទានសេដ្ឋកិច្ច ឬដីទាំងឡាយណាដែលមិនវិនិយោគ មិនប្រើប្រាស់ ត្រូវតែធ្វើការដកហូតមកវិញជាបន្តើរៗដើម្បីជាប្រយោជន៍របស់ជាតិ ។ ប្រសាសន៍នេះត្រូវបានទទួលការស្វាគមន៍ និង ការគាំទ្រពីគ្រប់មជ្ឍដ្ឋាន ។

ជាក់ស្តែង ក្រៅអំពីការបង្កឱ្យមានទំនាស់ ដែលធ្វើឱ្យស្មុគស្មាញដល់រាជរដ្ឋាភិបាល និង ការខាតបង់ធនធានរបស់រាជរដ្ឋាភិបាល ព្រមទាំងប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់រាជរដ្ឋាភិបាលក្នុងវិស័យសិទ្ធិមនុស្ស

ដីសម្បទានសេដ្ឋកិច្ចមិនគ្រាន់តែបានធ្វើឱ្យទីផ្សារដីធ្លីបាត់បង់មុខងាររបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានធ្វើឱ្យដីធ្លីបាត់បង់តួនាទីរបស់ខ្លួនក្នុងការចូលរួមចំណែកដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និង ការកាត់បន្ថយភាពក្រីក្រទៀតផង ។

ដីសម្បទានសេដ្ឋកិច្ច អាចរួមចំណែកដល់ការសម្រេចគោលដៅនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលបានល្អិកណាតែមានយន្តការមួយមានតម្លាភាព ដែលអនុញ្ញាតឱ្យមានការចូលរួមពិគ្រោះយោបល់ពីប្រជាពលរដ្ឋដែលពាក់ព័ន្ធ និង ប៉ះពាល់ ដោយធានាបាននូវអភិបាលកិច្ចល្អ និង បណ្ណាធិការកិច្ចថ្មីម្រត្រូវបើពុំនោះទេ កំហុសប្រវត្តិសាស្ត្រនឹងសារដានដូចជាកង់រទេះជាមិនខានឡើយ ។



